# ការសំភាសន៍របស់នាក់ស៊ុម ចុល

កះ អ្នកដែលសំភាសន៍ឈ្មោះថន រដ្ឋា ខះ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ស៊ុម ចុល

កះ បាទ! ថ្ងៃនេះទីប្រាំបួន ខែគុម្ភៈ ឆ្នាំពីពាន់ដប់ប្រាំបី ខ្ញុំបាទឈ្មោះថន រដ្ឋា នឹងធ្វើការសម្ភាសទៅកាន់អ្នកមីងស៊ុំ ចុលដែលបច្ចុប្បន្នអ្នកមីរស់នៅភូមិ ជ្រៃកោង សង្កាត់ស្លាកែត ក្រុងបាតដំបង ខេត្តបាត់ដំបង។ ហើយការសម្ភាសនេះគឺដើម្បីថែរក្សានូវប្រវត្តិរូបរបស់អ្នកមីងខ្លះដែលបានចែកចាយទុកអោយកូនចៅជំនាន់ក្រោយហើយសម្រាប់ក្រុមការងាររបស់ខ្ញុំដែលមកពីសាកលវិទ្យាល័យ(ពីវ៉ាយយូ)នឹងក៏ចងសិក្សារៀនសូត្រអំពីប្រជាពលរដ្ឋខ្មែរដែរ ថាប្រជាពលរដ្ឋខ្មែររស់នៅដូចម្តេច ជីវៈភាពគាត់យ៉ាងមេចអញ្ចឹណាស់ បាទ! ហើយអរគុណច្រើនអញ្ចឹងខ្ញុំសុមជម្រាបសួរអ្នកមីង!

ខះ ចាស៎!

កះ ហើយអ្នកមីង អ្នកមីងមានឈ្មោះពេញអីដែរអ្នកមីង?

ខះ ឈ្មោះនឹងឯងស៊ុមចុលអត់មានឈ្មោះក្រៅទេ ហើយអ្នកមីមានរហ័សនាមអត់អញ្ចឹង? អត់ផង អត់មានទេអូន។

កះ បាទ! អរគុណ ហើយសព្វថ្ងៃនេះអ្នកមីងមានអាយុប៉ុន្មានហើយ?

ខះ សែសឹបបួនឆ្នាំ។

កះ សែសឹបបួនឆ្នាំ អញ្ចឹងអ្នកមីងចាំថ្ងៃខែឆ្នាំកំណើតរបស់អ្នកមីងទេ?

ខះ ថ្ងៃខ្មែរអូន ខ្មែរក៏បារាំង?

កះ ខ្មែរក៏បាន បារាំងក៏បាន។

ខះ ថ្ងៃខ្មែរខែចៀស ថ្ងៃច័ន្ទ ឆ្នាំខាលឆ្នាំខ្មែរ។ អរគុណអ្នកមីងហើយអញ្ចឹងទីកន្លែងដែលអ្នកមីងបានកើតនូវក្នុងខេត្តភូមិឃុំណាដែល?

ខះ ភូមិបារណោះ ឃុំទំពរ ខេត្តតាកែវ។

កៈ ហើយអញ្ចឹងទាក់ទងនឹងសមាជិតក្រុមគ្រួសារវិញ អ្នកមីងមានបងប្អូនប៉ុន្មានអ្នកដែរ?

ខៈ ខ្ញុំមានបងប្អូនបួនអ្នក។

កៈ ហើយអ្នកមីងជាកូនទីប៉ុន្មាន?

ខៈ ខ្ញុំជាកូនទីពីរ។

កៈ
អ្នកមីងអាចជួយរៀបរាប់ពីបងរហូតដល់ប្អូនបានទេថាសព្វថ្ងៃគេរស់នៅឯណាកំពុងធ្វើអីខ្លះ
?

ខៈ បងប្រុសខ្ញុំនៅខាងប៉ៃលិន ឈ្មោះអីគេ ឈ្មោះស៊ុនស្រស់
ស៊ីឈ្នួលគេដែលនឹងធ្វើកម្មករអីនឹង ហើយផ្សេងទៀតនៅបាត់ដំបង
យើងនៅតែនៅស្រុករតនៈគីរី អ្នកដាំដំណាំ។

កៈ គាត់ឈ្មោះអីដែរ?

ស៊ុម ថុលៈ ប្អូនទីបីឈ្មោះស៊ុនប៊ុនឈឿន ទីបួនឈ្មោះ ស៊ុនវុទ្ធី
អ្នកស្រុករតនៈគីរីដូចគ្នាដែរខាងមុខខេត្តបាត់ដំបង។

កៈ ហើយអញ្ចឹងអរគុណច្រើនអ៊ំស្រីដែលបានចែកចាយហើយអ្នកមីងមានចងចាំ
អីអ្នកមីងចូលចិត្តធ្វើអីជាងគេកាលនៅពីក្មេងជាមួយបងប្អូនរបស់អ្នកមីងនឹងណា?

ខៈ ដូចជាភ្លេចអស់ហើយអត់ចាំទេ។

កៈ អញ្ចឹងចាំតែឈ្មោះហើយនឹងទីលំនៅគាត់រស់នៅ? ខៈ ចាំ!

កៈ អរគុណច្រើនអ្នកមីងអញ្ចឹងខ្ញុំចង់សាកសួរខ្លះទាក់ទងនឹងឪពុកម្តាយវិញហើយ
ហើយអ្នកម្តាយរបស់អ្នកមីងឈ្មោះអីដែរ?

ខៈ ម្តាយខ្ញុំឈ្មោះរឹមថុច។

ថន រដ្ឋា ហើយគាត់នៅខេត្តណាដែរ?

ខៈ គាត់នៅ ខូចបាត់ហើយ សួរគាត់ខូចឬក៏យ៉ាងមិច?

កៈ សួរគាត់រស់នៅឯណា?

ខ៖ ខេត្តកំណើតគាត់តាកែវនឹងដែរ?

ក៖  បាទ តែឥឡូវគាត់ខូចបាត់ហើយ គាត់អាយុប៉ុន្មានដែរ។

ខ៖ គាត់អាយុហុកសឹបប្រាំបីឆ្នាំ។

ក៖  ចុះលោកឪពុកឈ្មោះអីដែរ?

ស៊ុម ថុល៖ ឪពុកឈ្មោះជួនស្រេង។

ក៖  នៅខេត្តណា?

ខ៖ នៅខេត្តតាកែវនឹងដែរតែគាត់ខូចហើយ។

ក៖  ហើយគាត់ខូចកាល់ពីអាយុប៉ុន្មានដែរ?

ខ៖ គាត់ខូចអាយុចិតសឹបពីរ។

ក៖
អញ្ចឹងទាក់ទងនឹងមុខរបររបស់ពួកគាត់ប្រកប់មុខរបរចិញ្ចឹមគ្រួសារដោយយ៉ាងមិចដែរ?

ខ៖ ឪពុកខ្ញុំមុខរបរគាត់ពីមុនច្រើនណាស់គាត់ស៊ីឈ្នួលអូសទឹកគេ លក់អុសលក់អី
ចិញ្ចឹមគ្រួសារធ្វើស្រែធ្វើអីនឹង។

ក៖  បាទអ្នកស្រែចំការផងអ្នករកស៊ីផង បាទអរគុណច្រើនអ្នកមីងហើយ
អញ្ចឹងទាក់ទងនឹងអត្តចរឹករបស់ពួកគាត់យ៉ាងមិចដែរ?

ស៊ុម ថុល៖
ឪពុកខ្ញុំម៉ែខ្ញុំមនុស្សល្អញាតិជិតខាងចូលចិត្តស្រឡាញ់គាត់អត់ដែលចូលចិត្តរករឿងគេ។

ក៖  អរគុណច្រើនហើយអញ្ចឹងចាំថាពួកគាត់កើតថ្ងៃឆ្នាំណាទេ?

ខ៖ ឪពុកឆ្នាំរកា ម្ដាយឆ្នាំម្សាញ់ប៉ុន្នឹងឯង។

ក៖
ហើយអ្នកមីងមានចងចាំសាច់រឿងកាលដែលពួកគាត់នៅក្មេងគាត់មាននិយាយរឿងអីប្រាប់អ្នកមីងទាក់ទងនឹងពួកគាត់ដូចត់។

ខ៖ អត់ដែលនិយាយប្រាប់ផង ស្រឡាញ់គ្នាយ៉ាងមិចអញ្ចឹង អត់ដែល
អញ្ចឹងអរគុណច្រើនហើយ។

ក៖  អ៊ីជាបន្តទៀតខ្ញុំចង់ជម្រាបសួរអ្នកមីងទាក់ទងនឹងជីតាវិញម្តង
ហើយអញ្ចឹងជីដូនជីតាខាងម្តាយហើយនឹងជីតាខាងឪពុក
ហើយអ្នកមីងចាំឈ្មោះរបស់ពួកគាត់ទេ។

ខ៖ ខាងឪពុកឈ្មោះតាស៊ុមខាងពុកឈ្មោះយាយចាប់ តែអត់ដែលស្គាល់គាត់ទេ។

ក៖  ហើយផ្ទះរបស់គាត់នៅខេត្តណាដែរ?

ខ៖ ខេត្តតាកែវ។

ក៖ ពួកគាត់កាលពីដើមប្រកបមុខរបរអីដែរ?

ខ៖ គាត់គឺជាអ្នកស្រែចំការដែរ។

ក៖  ចុះជីដូនជីតាខាងម្តាយវិញ?

ខ៖ តាឈ្មោះ តារឹម ខាងយាយឈ្មោះ យាយឈឹលគាត់ស្លាប់អស់ហើយ។

ក៖ ហើយស្រុកកំណើតរបស់គាត់។

ខ៖ គាត់អ្នកតាកែវដែរ។

ក៖  អរគុណច្រើនអ្នកម្តាយមាននិយាយរឿងអីអំពីជីដូនជីតាថាគាត់ធ្វើអីធ្វើអីទេ?

ខ៖ ខាងម្តាយគាត់ប្រាប់ថាធ្វើស្រែធ្វើអីចាំ!

ក៖  គាត់ប្រកបរបរអីផ្សេងទៀតទេ
បាទអរគុណច្រើនជាបន្តទៀតខ្ញុំសុំសាកសួរទាក់ទងនឹងក្រុមគ្រួសារវិញម្តង
ហើយអ្នកមីងរស់នៅក្នុងខេត្តនឹងយូរហើយនូវ។

ខ៖ ខ្ញុំមកតាំងពីតូចចង់សែសឹបឆ្នាំដែរដឹងតាំងពីសម័យអាពតតាំងពីវៀតណាមចូល។

ក៖  ចុះកាលពីមុនអ្នកមីងរស់នៅជាមួយឪពុកម្តាយមែនទេ?

ខ៖ ចាំ! នៅពេលអ្នកមីងរស់នៅទីនោះជួយធ្វើការងារឬក៏គ្រាន់តែរស់នៅជាមួយគាត់ស្រុកឯណោះអី។

ក៖ បាទ ខ្ញុំអត់ចាំទេ ហើយអ្នកមីងមានសាច់ញាតិដែលរស់នៅក្រៅប្រទេសទេ?

ខ៖ អត់មានទេ។

ក៖ អត់មានទេណ៎?

ខ៖ ចាំ!

ក៖ អរគុណច្រើនអញ្ចឹងជាបន្តខ្ញុំចង់សាកសួរទាក់ទងទៅនឹងអាពាហ៍ពិពាហ៍វិញអញ្ចឹងតើស្វាមីរបស់អ្នកមីងឈ្មោះអីដែរ?

ខ៖ ឈ្មោះគឹមលាង។

ក៖ ហើយបានរៀបអាពាហ៍ពិពាហ៍រយៈពេលប៉ុន្មានហើយ?

ខ៖ ឆ្នាំមួយពាន់ប្រាំបួនរយកៅសិបប្រាំបីអូន។

ក៖  ចាំថ្ងៃខែទេ?

ខ៖ អត់ចាំភ្លេចបាត់ហើយ។

ក៖ ហើយចាំទីកន្លែងរៀបអាពាហ៍ពិពាហ៍ទេ?

ខ៖ នូវនឹងឯងនូវភូមិជ្រៃកោង សង្កាត់ស្លាកែប ក្រុងបាត់ដំបង ក្នុងខេត្តបាត់ដំបងនឹងចាំ!

ក៖
អរគុណច្រើនហើយទាក់ទងនឹងអាពាហ៍ពិពាហ៍ត្រូវបានរៀបចំដោយឪពុកម្តាយឬក៏ព្រោងព្រៀងគ្នា?

ខ៖ អត់ទេដោយឪពុកម្តាយខ្ញុំ។

ក៖  អំមិញយើងបានពិភាក្សាគ្នាអំពីអាពាហ៍ពិពាហ៍ចង់សួរអ្នកមីងថាកាលអញ្ចឹងអ្នកមីងខាន់ស្លាដម្រៅប៉ុន្មានដែរ?

ខ៖ ភ្លេចបាត់ហើយអូនអឺយ។

កៈ ប្រហែលជាប៉ុន្មាន?

ខៈ អត់ចាំទេ។

កៈ  អរគុណច្រើនអ្នកមីង
អញ្ចឹងអ្នកមីងអាចជួយប្រាប់ការស្គាល់គ្នាដំបូងដែលធ្វើអោយមីងចាប់ផ្តើមស្គាល់លោកពូអញ្ចឹងទៅណាដើម្បីរៀបការនឹងគ្នាអ្នកមីងអាចជួយប្រាប់ផង។

ខៈ ពូខ្ញុំអ្នកនាំមកចាំ!ពូខ្ញុំខាងជីដូនមួយម៉ែខ្ញុំនឹងឯងអ្នកនាំគាត់មក។

កៈ  ដំណែដំណូងយ៉ាងមិចដែរ?

ខៈ តែប៉ុន្នឹងឯងអត់មានអីទេ។

កៈ តែប៉ុន្នឹងឯងខ្លីប៉ុន្តែខ្លឹម។

ខៈ
បាទទាក់ទងនឹងភាសាវិញអ្នកមីងក្រៅពីភាសាខ្មែរអ្នកមីងមានចេះភាសារបរទេសអីទេ?

ខៈ ចាំ!អត់មានទេ។

កៈ
ហើយជាបន្តទៀតខ្ញុំចង់សាកសួរទាក់ទងដូចជាជីវៈប្រវត្តិខ្លះៗទាក់ទងនឹងការសិក្សាអីអញ្ចឹងណា អ្នកមីងបញ្ចប់ការសិក្សាត្រឹមថ្នាក់ទីប៉ុន្មាន។

កៈ ថ្នាក់ទី៨អូន។

កៈ នូវសាលាណាដែរ?

ខៈ សាលាចម្ការសំរោងយើង។

កៈ ខេត្តបាត់ដំបង។

ខៈ ចាំ!

កៈ  ហើយកាលនៅរៀនដូចជាវ័យជំទង់អ្នកមីងមានមិត្តភក្តិស្និទ្ធស្នាលទេ?

ខៈ ដូចជាមិនមានមិត្តិភក្តិជិតស្និតទេ អត់មានទេ តែគ្រាន់តែរាប់អានគ្នាធម្មតា។

កៈ ហើយចាំឈ្មោះពួកគាត់ទេ?

ខៈ ភ្លេចអស់ហើយឥឡូវនេះ។

កៈ តើពួកគាត់ឥឡូវនេះនៅឯណា?

ខៈ នៅយើងខាងជ្រៃកោងខាងពោធិ៍វង្សអត់ដឹងថាគេធ្វើអីខ្លះយូរៗជួបគ្នាម្តង។

កៈ ហើយចុះគាត់ឈ្មោះអីដែរ?

ខៈ ឈ្មោះអី ផាន្នី បងសារ៉ូន មុំ ណាគេ។

កៈ គាត់នៅក្នុខេត្តអីដែរ?

ខៈ ខេត្ត បាត់ដំបងយើងទាំងអស់ចាំ!

កៈ តើពួកគាត់ប្រគបមុខរបរធ្វើអីដែរ?

ខៈ ម្នាក់នោះលក់ត្រី ម្នាក់ទៀតលក់អីទេអត់ដឹង គ្រាន់តែឃើញមុខគ្នា។

កៈ  អរគុណអ្នកមីង
ហើយបន្តទៅទៀតអ្នកមីងធ្លាប់ចងចាំរឿងអីដែលធ្លាប់ដើរលេងជុំគ្នាទៅរៀនឬក៏ធ្វើការជុំគ្នាដើរលេងជំគ្នា?

ខៈ ដើរលេងដូចមិនដែលមាន ទៅរៀនមានតែយើងចេញលេងយើងលេងសើចធម្មតាមានតែប៉ុណ្ណោះឯង។

កៈ  ចូលចិត្តធ្វើអីជុំគ្នាជាមួយមិត្តិភក្តិ?

ស៊ុម ចុលៈ
វាមិនមានពេលអីឲ្យបានធ្វើអីជុំគ្នាផងជំនាន់នឹងមានដូចជំនាន់នេះយើងដើរជំនាន់នោះវាអត់មានអីជិះដើរសុទ្ធតែដីផ្លូក។

កៈ ដើរកាត់ផ្លូក?

ខៈ ចាស៎! ដើរកាត់ផ្លូកមែនតើ ផ្លូវនេះអត់ទាន់ធ្វើដើរកាត់ភ្លឺស្រែនឹងទៅរៀនជំនាន់នឹង។

កៈ  បាទ! អញ្ចឹងអគុណច្រើន
ទាក់ទងនឹងក្រុមគ្រួសាររបស់អ្នកមីងជាលក្ខណ:ជនបទក៏នៅទីក្រុង។

ខៈ គ្រួសារពុកម៉ែខ្ញុំហី?

កៈ បាទ!

ខៈ  រាល់ថ្ងៃនេះ រៀបអ្នកស្រែចំការអត់មែនរបៀបអ្នកក្រុងផង។

កៈ   ដូចនៅជាយដែនក្រុង។

ខៈ ចាស់! អរគុណអ្នកមីង
ហើយទាក់ទងនឹងមុខរបរវិញអ្នកមីងបានធ្វើអីខ្លះសម្រាប់ប្រកបមុខរបរចិញ្ចឹមជីវិតក្រុមគ្រួសារ? ខ្ញុំពីដើមខ្ញុំរកអេតចាយ ទើបអីឡូវខ្ញុំឈឺ ចាប់ពីញុំឈឺខ្ញុំឈប់រកអេតចាយ
លក់បន្តិចបន្តួចនោះឯងតែប៉ុនោះឯង។

កៈ  អញ្ចឹងក្រៅពីការងារអ៊ី ក្រៅពីការរើសអេតចាយ។ ស៊ុម ថុលៈ ដើរទិញអេតចាយ។

ខៈ អុះ! ទិញអេតចាយទិញអេតចាយសុំទោស។

រើសអេតចាយទិញអេតចាយខុសគ្នាណាំ?

កៈ
អញ្ចឹងក្រៅពីមុខរបរនោះអ្នកមីងអាចធ្វើអីដើម្បីរកចំណូលសម្រាប់ចីញ្ចឹមក្រុមគ្រួសារទេ?

ខៈ ដូចជាអត់ដែលមានផង ទិញតែអេតចាយមួយមុខនោះ នៅជំនាន់នោះ ចាំ!

កៈ  ចុះឥឡូវវិញ?

ខៈ ឥឡូវលក់ដូរបន្តិចបន្តួចនៅផ្ទះនោះឯង។

កៈ  ធ្វើអាជីវកម្មនៅផ្ទះ?

ខៈ ចាំ!

កៈ
ហើយតាំងពីក្មេងរយហូតមកដល់ពេលនេះអ្នកមីងគឺតថាជីវិតមានការប្រែប្រួលអីធំដំទេ?

ខ៖ ដូចជាមិនមានអីផ្លាស់ប្តូធំដុំទេអូនអើយ បានតែម្ហូបៗដូចពីមុនដែរ អត់មានអីសល់។

ក៖  អញ្ចឹងបាននិយាយរឿងម៉ាហូបអញ្ចឹងមីងចូលចិត្តពិសារម្ហូបអីដែរ?

ខ៖ ម្ហូបសម្លកកូរ ទឹកគ្រឿងអី ម្ហូបខ្មែរ ស្លម្ជូរ។

ក៖ បង្អែម។

ខ៖ អត់ចូលចិត្តបង្អែមទេ។

ក៖  ហើយចុះប្រៃ?

ខ៖ អត់ចូលចិត្តប្រៃដែរ។

ក៖ ចុះចត់ល្វីង។

ខ៖ ចត់ល្វីងអត់។

ក៖ ចុះផ្នែកកីឡាវិញមានចូលចិត្តកីឡានិងល្បែងប្រជាប្រិយវិញ តើចូលចិត្តរបៀណាដែរ ឬក៏ហ្គេមអី?

ខ៖ ចូលចិត្តមើលល្បែងប្រជាប្រិយ៍។

ក៖  ដូចជាល្បែងអីខ្លះដែរ?

ខ៖ ទាញព្រាត់ដណ្តើមស្លឹកឈើអី។

ក៖  ហើយទាក់ទងនឹងចំរៀងវិញអ្នកមីងចូលចិត្តចម្រៀងអីដែរ?

ខ៖ ចំរៀងសម័យដើម។

ក៖  បទអីដែរ?

ខ៖ លោកតា ស៊ីនស៊ីសាមុត។

ក៖  ចាំបានចំណងជើងបទចំរៀងទេ?

ខ៖ អត់ដែលចាំទាល់តែលឺគេច្រៀង។

ក៖  អរគុណអ្នកមីងក្នុងក្រុមគ្រួសារឬក៏បងប្អូនអីមានអ្នកចេះលេងឧបក្ករណ៍តន្ត្រីទេ?

ខ៖ អត់មានផងទេអូន។

ក៖  អញ្ចឹងកាលអឹអ្នកមីងនៅក្មេងផ្ទះរបសើអ្នកមីងជាផ្ទះរបស់អ្នកមីងជាផ្ទះយ៉ាងមេចទៅ?

ខ៖ ផ្ទះគេហៅផ្ទះប្រក់គ្របូលស្លឹក ផ្ទះកន្តាំង ផ្ទះទាប ដំបូលប្រក់ស្លឹក។

ក៖  ជញ្ជាំង។

ខ៖ ជញ្ជាំងស្លឹកដូង។

ក៖  សសរ។

ខ៖ សសរឈើ។

ក៖  អញ្ចឹងផ្ទះនេះឪពុកម្តាយជាអ្នកធ្វើ។

ខ៖ ដូចជារកបងប្អូនធ្វើជំនាន់នោះស្រួល។

ក៖  គេប្រើសម្ភារៈអីខ្លះសម្រាប់ធ្វើផ្ទះនោះ?

ខ៖ ភ្លេចបាត់ហើយតាំងពីទូច។

ក៖  ហើយអញ្ចឹងអ្នកមីងមានបានរៀនជំនាញអ្វីតពីឪពុកម្តាយទេ។

ខ៖ អត់មានជំនាញអីផងអូន។

ក៖  ដូចជាត្បាញកន្ទេល។

ខ៖ អត់! ខ្ញុំអត់ចេះផងអត់ទាំងអស់។

ក៖  អរគុណអ្នកមីងហើយសូមបន្តបន្តិចទៀត
តើនៅក្នុងជីវិតរបស់អ្នកមីងតាំងពីក្មេងរហូតមកដល់ឥឡូវមានធ្លាប់ជួបបញ្ហាលំបាក់បំផុតនៅក្នុងជីវិតរបស់អ្នកមីងទេ?

ខ៖ មានតើអូន ពិបាកបិបាកនៅពេលដែលយើងអត់លុយអត់កាក់ហ្នឹងពិបាកចាស!

ក៖  ការហើយគឺអត់មានលុយម៉ង?

ខ៖ ចាស! ធ្វើមេចទៅ?

កៈ ចេះតែខំប្រឹងទាំងអស់គ្នា។

ខៈ ទោះយើងនៅជាមួយម្ដាយខិតខំ ចាស!

កៈ អរគុណ។

ខៈ អញ្ចឹងយើងឆ្លងកាត់វាដោយការខំប្រឹងប្រែង។

កៈ អញ្ចឹងជាបន្តទៀតទាក់ទងនឹងអើ
ទាក់ទងនឹងបទពិសោធន៍ល្អៗវិញមានអីដែលចែកចាយទាក់ទងនឹងបទពិសោធន៍ល្អៗហើយសប្បាយចិត្តមានទេ?

ខៈ បទពិសោធន៍ល្អៗ។

កៈ
ខ្ញុំថាមនុស្សម្នាក់ៗទាល់តែប្រឹងប្រែងបានជោគជ័យបើមិនខំប្រឹងប្រែងអត់បានជោគជ័យទេ។

ខៈ អត់ដែលបានជោគជ័យព្រោះម៉ែឪយើងក្រៗ អត់ដែរស្គាល់
អត់ស្គាល់អត់ដែលស្គាស់សោះ
មានតែចូលក្នុងផ្ទូកអត់ដែលសោះនៅតូចៗមានតែខែវស្សាចូលផ្ទូក មិនមាន។

កៈ បាទអរគុណអ្នកមីង កាលនៅក្នុងអ្នកមីងធ្លាប់រំពឹងចង់ធ្វើអីសម្រាប់ពេលធំឡើងទេ?

ខៈ អត់ដែលហ៊ានស្រមៃព្រោះអត់ដែលមានសង្ឃឹម។

កៈ
អរគុណច្រើនអ្នកមីងដែលបានផ្ដល់ឪកាសខ្លះអោយខ្ញុំបានសម្ភាសអំពីប្រវត្តិអញ្ចឹងនោះណា។
ហើយដូចខ្ញុំបានជម្រាបថាគោលបំណងនេះគឺសាកលវិទ្យាល័យ(BYU)រក្សាទុកឯកសារជូនអ្នកមីងហើយនឹងជូនអហានកមីងជា cv
ហើយការសម្ភាសមួយនេះខ្ញុំមានប្រធានរបស់ខ្ញុំគាត់ចេះភាសារខ្មែរច្បាស់លាស់ផងដែរ
ហើយបើនាកមីងចង់ទាកទងគាត់អាចទាក់ទងតាមខ្ញុំក៏បានតាមរយៈខ្ញុំអញ្ចឹងណាស់
ឬក៏តាមលេខទូរស័ព្ទ
ហើយមួយវិញទៀតគឺខ្ញុំអរគុណអ្នកមីងច្រើនសម្រាប់ឪកាសថ្ងៃនេះហើយអ្នកមីងមានអីជា

សំណូមពរដល់កូនចោជំនាន់ក្រោយឬក៏ជមនាន់នេះគាត់ធ្វើមេចៗអញ្ចឹងណ៊ា។
ចង់ដែរចេងសំណូមពរអោយកុនចៅជំនាន់ក្រោយចេះ ចង់ចេះដឹងអោយជ្រៅជ្រះម្ទង
កំអោយល្ងង់ជាងប្រទេសគេមានតែប៉ុណ្ណឹងឯង។

ខ៖ ចាស!

ក៖  អរគុណច្រើនសូមជំរាបលា។

ខ៖ ចាស!អរគុណៗ។